**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខ: ១៣...៩៨..៥..៣៨**

# សារលិខិតជូនពរ

## សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា នៅក្នុងឱកាសប្រារព្ធខួបកំណើតគម្រប់ ៦៣ឆ្នាំ ឈានចូល ៦៤ឆ្នាំ

**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់**

នៅក្នុងឱកាសដ៏មង្គលសួស្តីប្រសើរថ្លៃថ្លា ប្រកបដោយមនោសញ្ចេតនាសោមនស្សរីករាយ នៃ**ឱកាសប្រារព្ធខួបកំណើតគម្រប់ ៦៣ឆ្នាំ ឈានចូល ៦៤ឆ្នាំ** ដែលនឹងប្រព្រឹត្តទៅនៅ**ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧** ខាងមុខនេះ **របស់សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** តាងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់នៃទីស្តីការគណៈរដ្ឋមន្ត្រី ខ្ញុំ និងភរិយា សូមសម្តែងនូវសេចក្តីអំណរសាទរដ៏ស្មោះអស់ពីដួងចិត្ត និងសូមចូលរួមជូននូវសព្ទសាធុការពរជ័យ បវរសួស្តី សិរីវឌ្ឍនា វិបុលសុខ មហាប្រសើរគ្រប់យ៉ាង និងសូម**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** បានសមប្រកបដោយ កាយពលរឹងមាំខ្លាំងក្លា បញ្ញាញាណភ្លឺថ្លាត្រចះត្រចង់ សុខភាពល្អបរិបូរណ៍ ជន្មាយុយឺនយូរ **ដើម្បីដឹកនាំកាកបាទក្រហមកម្ពុជា**ឱ្យទទួលបាននូវលទ្ធផលផ្លែផ្កាដ៏ត្រចះត្រចង់ថ្មីៗធំធេងថែមទៀត ជាពិសេសក្នុងកិច្ចខិតខំប្រឹងប្រែងស្វះស្វែងរកជំនួយមនុស្សធម៌ពីគ្រប់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ ដើម្បីជួយដល់ទុរគតជន ជនចាស់ជរា ជនងាយរងគ្រោះ កុមារកំព្រា ជនគរថ្លង់ យុទ្ធជនរបួស ជនពិការ និងជនរងគ្រោះដោយសារគ្រោះធម្មជាតិ និងគ្រោះមហន្តរាយផ្សេងៗ។

យើងខ្ញុំទាំងអស់គ្នាសូមគោរពថ្លែងនូវអំណរសាទរ ការកោតសរសើរ និងការដឹងគុណយ៉ាងជ្រាលជ្រៅ ប្រកបដោយកតញ្ញូកតវេទិតាធម៌យ៉ាងស្មោះស្ម័គ្របំផុត ចំពោះបញ្ញាញាណដ៏ឈ្លាសវៃ សកម្មភាពប្រកបដោយគុណធម៌ និងមនុស្សធម៌**របស់សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ក្នុងការចូលរួមចំណែកដ៏មានតម្លៃថ្លៃថ្លា ជួយដោះស្រាយទុក្ខលំបាក និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនជាមួយរាជរដ្ឋាភិបាលកម្ពុជា។ ទាំងនេះគឺជាសមិទ្ធផល និងស្នាដៃយ៉ាងធំធេងរបស់**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ដែលខិតខំសម្រេចបានក្នុងបុព្វហេតុជាតិមាតុភូមិ និងប្រជាជនកម្ពុជា។

**សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត**គឺជាកុលធីតាខ្មែរដ៏ឆ្នើមមួយរូប ជាស្ត្រីដឹកនាំគំរូល្បាញល្បីដែលប្រកបដោយសីលធម៌ គុណធម៌ និងទេពកោសល្យដ៏ឧត្តុង្គឧត្តមថ្លៃថ្លារបស់ជាតិមាតុភូមិកម្ពុជា ព្រមទាំងជាឧត្តមភរិយាដ៏ប្រពៃថ្លៃថ្លា ជាមាតា និងជីដូនប្រកបដោយចរិយាធម៌ និងព្រហ្មវិហារធម៌យ៉ាងវិសេសវិសាលបំផុត។

ឆ្លៀតក្នុងឱកាសដ៏មហានក្ខត្តឫក្សវិសេសវិសាលនេះ យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃទីស្ដីការគណៈរដ្ឋមន្ត្រីជាថ្មីម្ដងទៀត សូមលើកហត្ថប្រណម្យសូមដល់ទេព្ដាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក គុណបុណ្យព្រះរតនត្រ័យគុណកែវទាំងបី ឫទ្ធិបារមីខ្លាំងក្លា បុណ្យបារមីដែល ថែរក្សាប្រាង្គប្រាសាទអង្គរ ព្រះអង្គចេក ព្រះអង្គចម សូមព្រះអង្គតាមជួយថែរក្សាការពារប្រោះព្រំ **ជូនសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត និងសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បុត្រា បុត្រី បុត្រប្រសារ ចៅប្រុស ចៅស្រី ជាទីស្រឡាញ់ សូមបានប្រកបដោយពុទ្ធពរដ៏ប្រសើរថ្លៃថ្លាទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ ជានិច្ចនិរន្តរ៍កុំបីឃ្លៀងឃ្លាតឡើយ។

សូម**សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ និងអភិវន្ទនកិច្ចដ៏ស្មោះស្ម័គ្របំផុតពីខ្ញុំ និងភរិយា។

ថ្ងៃ ១៥ រោច ខែមិគសិរ ឆ្នាំរកា ព.ស ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០១៧

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃទីស្តីការគណៈរដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**ប៊ិន ឈិន**